## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍
# កិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែមីនា ឆ្នាំ២០២២
# ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី

១)- **ថ្ងៃ ខែ ឆ្នាំ៖** នាព្រឹកថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។

២)- **ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣)- ប្រធាន និងសមាសភាពចូលរួម ៖

- ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ឯកឧត្តម លោកជំទាវ ជាអនុប្រធាន អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គលេខាធិការរង ទីប្រឹក្សា ជំនួយការប្រធាននាយកដ្ឋាន នៅក្នុងសាលប្រជុំ "ខ" ។
- លោក អ្នកស្រី អ្នកនាងកញ្ញា អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុការិយាល័យ ព្រមទាំងមន្ត្រីនៃ អ.ជ.ប.ជ.អ ចូលរួមតាមបណ្តាញវីដេអូ កម្មវិធី Zoom។

៤)- របៀបវារៈ ៖

- បទបង្ហាញរបាយការណ៍សង្ខេបស្តីពីលទ្ធផលសកម្មភាពការងារប្រចាំខែមីនា និងទិសដៅការងារខែមេសា ឆ្នាំ ២០២២ ដោយឯកឧត្តម **ឈឹម យិនដារ៉េត**។
- បទបង្ហាញ ស្តីពីការសម្របសម្រួល ដើម្បីបញ្ចប់ការរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ នៅឆ្នាំ២០២៥ ដោយ ឯកឧត្តម **រស់ សីលវ៉ាត់**។
- មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី
- កិច្ចការផ្សេងៗ។

៥)- លទ្ធផល ៖

១). **បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន**

ក- សកម្មភាពការងារដែលសម្រេចបាន ៖

- បានប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ពិនិត្យវឌ្ឍនភាពការងារ និងដាក់ទិសដៅ។

- បានរៀបចំរបាយការណ៍ស្តីពីការតាមដានការរាលដាលមេរោគអេដស៍សកលឆ្នាំ២០២១ (Global AIDS Monitoring 2021)។
- បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការត្រួតពិនិត្យតាមដានការអនុវត្តសេចក្តីណែនាំ សជណ ២១៣ (ខេត្តបន្ទាយមានជ័យ សៀមរាប បាត់ដំបង និងកំពង់ចាម)។
- ចូលរួមបើកអង្គសិក្ខាសាលាស្តីអំពីការបង្កើតសារអប់រំសម្រាប់អ្នកអប់រំផ្ទាល់ និងអ្នកផ្តល់សេវាសុខភាពសហគមន៍ និងពិធីផ្សព្វផ្សាយនៃការអនុវត្តគម្រោង។
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ និងរៀបចំកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស) ៣ ឆ្នាំរំកិល រៀបចំដោយក្រសួងផែនការ នៅខេត្តសៀមរាប។
- ចូលរួមកិច្ចប្រជុំពិនិត្យសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ២០១៩-២០២៣ រៀបចំដោយក្រសួងផែនការ។
- បានកែសម្រួលសូចនាករមួយចំនួននៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ដែលត្រូវដាក់បញ្ចូលក្នុងសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ២០១៩-២០២៣ រៀបចំដោយក្រសួងផែនការ។
- បានផ្តល់ធាតុចូលលើសេចក្តីព្រាងចុងក្រោយឯកសារគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ តាមសំណើរបស់ក្រសួងកិច្ចការនារី។
- បានធ្វើការទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានថវិការដ្ឋបាលថ្នាក់ក្រោមជាតិអំពីការរៀបចំសេចក្តីព្រាងប្រកាសស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- បើកវគ្គបណ្តុះបណ្តាលស្តីពីជំនាញពង្រឹងស្ថាប័នក្នុងការតាមដានលើការអនុវត្តលិខិតលេខ២១៣ សជណ.សស នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ។
- បានប្រជុំក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ. លើកទី៣ ឆ្នាំ២០២២។
- បានអនុវត្តគម្រោងមូលនិធិសកលៈ សិក្ខាសាលា៣លើក ប្រជុំ១លើក និងបេសកកម្ម៤លើក។
- បានដំណើរការថវិកាជាតិតាមនីតិវិធីហិរញ្ញវត្ថុ សំណើសុំថវិកា ទូទាត់ថវិកា និងដកថវិកាបានចំនួន៧លើក។

## ខ- បញ្ហាប្រឈម ៖

ភាពធូរស្រាលនៃស្ថានភាពជំងឺកូវីដ-១៩ បានធ្វើឱ្យសកម្មភាពនៃការចុះបេសកកម្មនៅតាមបណ្តាខេត្តមានការកើនឡើង អាចប៉ះពាល់ដល់ការផ្គត់ផ្គង់រថយន្ត និងមន្ត្រី។

## គ- ទិសដៅអនុវត្តបន្ត៖

- បន្តអនុវត្តសកម្មភាពតាមផែនការសកម្មភាពអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ. ឆ្នាំ២០២២។
- បន្តចុះបណ្តុះបណ្តាលការត្រួតពិនិត្យការអនុវត្តសជណ២១៣ តាមបណ្តារាជធានី ខេត្តគោលដៅ។
- បន្តសហការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍តាមបណ្តារាជធានី ខេត្តគោលដៅ។

- ចងក្រង និងបញ្ជូនទិន្នន័យរៀបចំរបាយការណ៍ស្តីពីមេរោគអេដស៍សកលឆ្នាំ២០២១ (Global AIDS Monitoring 2021) (Global AIDS Monitoring 2021)
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី៤។
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់កម្រិតបច្ចេកទេស ដើម្បីប្រមូលធាតុចូលរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រុងប្រយ័ត្នជាសកល ចំពោះការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS)។
- រៀបចំប្រជុំក្រុមការងារវាយតម្លៃលក្ខណសម្បត្តិគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី។

ឃ- ការបង្ហាញនូវការរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការលុបបំបាត់ការចម្លងមេរោគអេដស៍ពីម្តាយទៅទារក

**២). បទបង្ហាញ ស្តីពីការសម្របសម្រួល ដើម្បីបញ្ចប់ការរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ នៅឆ្នាំ ២០២៥ ដោយ ឯកឧត្តម វស់ សីលវ៉ាត់។**

- សម្តេចប្រមុខរាជរដ្ឋាភិបាល បានប្តេជ្ញាចិត្ត និងណែនាំអោយរួមគ្នាជាចរន្តជាតិតែមួយឆ្ពោះទៅបញ្ចប់ជំងឺអេដស៍ នៅឆ្នាំ២០២៥។
- ក្នុងន័យនេះ **គោលដៅ** ប្រទេសជាតិយើងត្រូវធ្វើអោយសម្រេចគឺ
    - សម្រេចបានគោលដៅ៩៥-៩៥-៩៥។
    - ត្រៀមលក្ខណៈដើម្បីធានានិរន្តរភាពនៃការឆ្លើយតបទៅនឹងជំងឺអេដស៍តាមរយៈការពង្រឹងប្រព័ន្ធជាតិមួយដែលទ្រទ្រង់អន្តរាគមន៍ឆ្លើយតបបានដោយការទទួលខុសត្រូវខ្ពស់ និងមានវិធីសាស្ត្របង្កើនការវិនិយោគធនធានក្នុងស្រុក បន្ថយការពឹងផ្អែកជំនួយពីក្រៅ និងបង្កើនភាពជាម្ចាស់ការ
- **ក្របខ័ណ្ឌគោលនយោបាយនិងយុទ្ធសាស្ត្រ** សម្រាប់គាំទ្រដំណើរឆ្ពោះទៅសម្រេចគោលដៅនេះយើងមានៈ
    - ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (NSPV) ដែលទើបធ្វើការពិនិត្យពាក់កណ្តាលអាណត្តិថ្មីៗ។
    - សេចក្តីជូនដំណឹងលេខ២១៣ ស.ជ.ណ ចុះថ្ងៃទី២១ ខែកុម្ភះ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- **ចំនុចប្រឈម** ចំបងៗមួយចំនួនដែលត្រូវផ្តោតការយកចិត្តទុកដាក់ៈ
    - ចំណុចប្រឈម ទី១ គឺការឆ្លងថ្មី ការបោះបង់សេវាព្យាបាល អត្រាស្លាប់ និងអ្នកនៅក្រៅប្រព័ន្ធនៅខ្ពស់
        - ឆ្លងថ្មី ដល់ ១១០០នាក់ក្នុង១ឆ្នាំ
        - បោះបង់ការព្យាបាលដល់ប្រហែល១២% រឺ៨០០០នាក់ក្នុង១ឆ្នាំ
        - ស្លាប់ដល់១២០០នាក់ក្នុង១ឆ្នាំ)
        - នៅក្រៅប្រព័ន្ធដល់ ១២០០០នាក់។
    - ចំណុចប្រឈមទី២ គឺធានាចីរភាព ដោយៈ
        - ពង្រឹងប្រព័ន្ធ ដើរចេញពីការអនុវត្តតែកម្មវិធី ឆ្ពោះទៅការកសាងនិង/រឺពង្រឹងប្រព័ន្ធ បន្ថែមលើការអនុវត្តកម្មវិធី
        - បន្ថយការពឹងផ្អែកលើជំនួយពីខាងក្រៅ និងបង្កើនថវិកាជាតិបដិភាគ ដែលតាមផែនការ អោយបាន៥០% នៅឆ្នាំ២០២៣។
- **អន្តរាគមន៍អាទិភាពគឺៈ**
    - បង្កើនការងារបង្ការសំខាន់ គឺផ្តោតទៅលើក្រុមប្រឈម ការឆ្លងពីម្តាយទៅកូន និងអ្នកកើតជំងឺបេង។

- ផ្លាស់ប្តូរពីអភិក្រមនៃការផ្តល់សេវាទាំងឡាយដែលចេញពីគំនិតរបស់អ្នកផ្តល់សេវា ទៅជាសេវាដែលផ្តោតទៅលើផលប្រយោជន៍របស់ប្រជាជនរងគ្រោះជាធំ។
  - ជានាបង្កើនការវិនិយោគក្នុងស្រុក ដើម្បីគាំទ្រប្រព័ន្ធទៅថ្ងៃអនាគត។
  - បន្តរក្សាយន្តការសម្របសម្រួលតែមួយ ផែនការយុទ្ធសាស្ត្រតែមួយ និងមានM&E frameworkតែមួយ

- **យន្តការសម្របសម្រួលសម្រាប់អន្តរាគមន៍ទាំង៣០** (យុទ្ធសាស្ត្រទី១ មានចំនួន៩ ទី២ មានចំនួន៥ ទី៣ មានចំនួន៧ និងទ៤ មានចំនួន៩) មាន:
  - ក្រុមការងារទទួលបន្ទុកតាមយុទ្ធសាស្ត្រនីមួយៗ ជាអ្នកសម្របសម្រួល តាមដាន និងជាអ្នកដឹកនាំអនុវត្តឱ្យបានសម្រេចអន្តរាគមន៍ក្នុងយុទ្ធសាស្ត្រ។
  - លទ្ធផល និងវឌ្ឍនភាពត្រូវរាយការណ៍ចូលកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស។
  - ក្រុមប្រឹក្សាបច្ចេកទេសត្រូវពិគ្រោះយោបល់ជាមួយក្រុមការងាររាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដើម្បីស្វែងរកដំណោះស្រាយ រួចដាក់ជូនមកកិច្ចប្រជុំថ្នាក់ដឹកនាំជាន់ខ្ពស់របស់អាជ្ញាធរជាតិ ហើយបន្តទៅក្រុមប្រឹក្សាគោលនយោបាយ ដែលជាកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីជ្រាបពីវឌ្ឍនភាព និង/ រឺធ្វើការសម្រេចចិត្តដាក់ចេញនូវគោលនយោបាយចាំបាច់ផ្សេងៗ។
  - ក្នុងការងារសម្របសម្រួល ក្រុមការងារត្រូវប្រកាន់នូវ:
    - ទី១ *ពង្រឹងភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់ការ* (Leadership and ownership) ទី២ )- *ភាពជាដៃគូ* (Partnership) ទី៣ )- *ការវិនិយោគ* (Investment)។
    - គោលការណ៍ដាក់មនុស្ស និងសហគមន៍ នៅចំណុចកណ្តាលនៃការឆ្លើយតបនឹងជំងឺអេដស៍។
    - ឈរលើអភិក្រមនៃការពង្រឹងប្រព័ន្ធសុខាភិបាលៈ governance, information, finaning, service delivery, human resource, and medicine/technology សម្រាប់គាំទ្រអន្តរាគមន៍នីមួយៗក្នុងយុទ្ធសាស្ត្រទាំង៤ ដែលក្រុមការងារលើកមករកដំណោះស្រាយ។
    - មន្ត្រីទាំងអស់ត្រូវមានជំនាញទន់ (Soft Skills) ក្នុងការងារដឹកនាំ និងគ្រប់គ្រង។

## ៤). មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី

ឯកឧត្តមទេសរដ្ឋមន្ត្រី បានមានប្រសាសន៍សំណេះសំណាល និងផ្តល់នូវអនុសាសន៍លើចំណុចសំខាន់ៗដូចខាងក្រោម ៖

- អបអរសាទរចំពោះលទ្ធផលអង្គប្រជុំក្រុមប្រឹក្សាបច្ចេកទេស។
- លើកទឹកចិត្តដល់ក្រុមប្រឹក្សាបច្ចេកទេសអោយបន្តស្វែងយល់អំពីស្ថានភាពនៃអត្រាចម្លងពីមាតាទៅទារក ជួយសម្រួលដំណោះស្រាយពាក់ព័ន្ធការកែលម្អការការពារការចម្លងមេរោគអេដស៍ទៅទារក។
- អគ្គលេខាធិការត្រូវខិតខំបន្តសកម្មភាពជំរុញអនុវត្ត*គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍* (Fast Track City) ឱ្យបានទូលំទូលាយ ជាពិសេសទំនាក់ទំនងប្រកាសក្រសួង ដើម្បីកំណត់អំពីការប្រើប្រាស់ថវិកា៨០លានរៀល ពាក់ព័ន្ធ និងការប្រជុំ សិក្ខាសាលា បំពាក់បំប៉ន បេសកកម្ម និងពង្រីកទៅខេត្តឯទៀត។
- ខិតខំលើកទឹកចិត្តឱ្យជំរុញការរុករកអ្នកផ្ទុកមេរោគអេដស៍ដែលមិនទាន់ចូលក្នុង ៩៥ ទី១។
- ខិតខំលើកទឹកចិត្តជំរុញការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ ដល់*ក្រុមគោលដៅ* MSM, TG, EW PWD etc.។

- អគ្គលេខាធិការ ត្រូវខិតខំតាមដានអំពីការរៀបចំអនុក្រឹត្យស្តីពីសុវត្ថិភាពជាសកលក្នុងការវះកាត់ក្រៅប្រព័ន្ធសុខាភិបាល។
- អគ្គលេខាធិការត្រូវខិតខំធ្វើការទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្នុងការធ្វើអោយដំណើរការកម្មវិធីអេដស៍ ជាពិសេសសកម្មភាពការងារ និងការលើកគម្រោងថវិកាការងារអេដស៍។
- ការងារផ្សព្វផ្សាយសកម្មភាពរបស់ថ្នាក់ដឹកនាំ ផ្នែកការងារបក្សត្រូវដកចេញពី គេហទំព័រ (Website) & Page Facebook ចេញពីទំព័រផ្លូវការរបស់ អ.ជ.ប.ជ.អ ប៉ុន្តែផ្សព្វផ្សាយក្នុង Facebook របស់គណៈកម្មាធិការគណៈបក្ស អ.ជ.ប.ជ.អ និងក្រុមការងារយុវជនគណបក្ស អ.ជ.ប.ជ.អ ។
- សម្រាប់ថវិកាមូលនិធិសកល (GF) ត្រូវខិតខំប្រើប្រាស់ថវិកាសម្រាប់ អ.ជ.ប.ជ.អ អោយបានច្រើនជាទីបំផុត ដូចជាការធ្វើសិក្ខាសាលាពង្រឹងរចនាសម្ព័ន្ធ គណៈកម្មាធិការឃុំ សង្កាត់។
- ត្រូវរៀបចំប្រជុំគណៈកម្មាធិការ វាយតម្លៃការងារអេដស៍នៃសមាជិក អ.ជ.ប.ជ.អ. ស្តីពីនីតិវិធីកំណត់លក្ខណសម្បត្តិនៃការផ្តល់រង្វាន់ដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង និងរាជធានី ខេត្ត ដោយដាក់ពិន្ទុលើ ៖
    - ទី១) របាយការណ៍ ៖ របាយការណ៍ផ្តល់ជូនទាន់ពេលវេលា គ្រប់ជ្រុងជ្រោយ
    - ទី២) ខ្លឹមសារការងារ៖ សកម្មភាពចំគោលដៅ ចេះច្នៃប្រឌិត សកម្មមានថវិកា
    - ទី៣) ដំណើរការ ៖ ការបង្ការ ការរុករក និងការពារអនិតិជន
- ប្រជុំក្រុមការងារយុទ្ធសាស្ត្រ ***ស្តីពីការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ*** (Mild term review) នៃ ***ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥*** នៅខែឧសភា ឆ្នាំ២០២២ ឱ្យបានមុនប្រជុំ GDJ Technical Working Group។
- អាចប្រជុំជាមួយក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល UNAIDS ចេញនូវការកំណត់ពន្យល់ (Explanatory note) អំពី 95-95-95 និង 10-10-10។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការអនុវត្តការងារឱ្យចំទិសដៅ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមយន្តការយុទ្ធសាស្ត្រនីមួយៗឱ្យកាន់តែប្រសើរឡើង។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១:២៧នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២
អ្នកធ្វើរបាយការណ៍

ស៊ុត_ថិនផាន់

បានឃើញ និងឯកភាព
ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

អៀង_មូលី